ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿង ព្រហ្មទណ្ឌ

លេខ ៖ ៦០

ចុះថ្ងៃទី ១៦-០៩-១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

សាលដីកា

លេខ ៖ ៦០

ចុះថ្ងៃទី ១៨-១០-២០០០

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ ៖

១-ឯកឧត្តម ឃឹម បុណ្ណ ជាប្រធាន

២-លោក ឈឹម ស៊ីផល ជាចៅក្រមរបាយការណ៍

៣-លោក សោម សិរីវឌ្ឍ ជាចៅក្រម

៤-លោក ជីវ កេង ជាចៅក្រម

៥-លោក ស៊ុន ឌឹម ជាចៅក្រម

លោក វ៉ាត់ បូរ៉ាត ជាក្រឡាបញ្ជី

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនទៀង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ១៦៤ ចុះថ្ងៃទី ២៥-៦-១៩៩៩ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ៦០ ចុះថ្ងៃទី ១៦-៩-១៩៩៩ របស់តុលាការកំពូល។

ពិរុទ្ធ ៖ សម្លាប់មនុស្សគិតទុកជាមុន និង ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី០៦-០៨-១៩៩៦ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៣១ និង ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះ ឃុន សុធី ហៅ ក្ដាម "ម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រែកច ស្រុកពញាព្រែកច ខេត្តកំពង់ចាម មុខរបរ នគរបាលព្រំដែន ប្រចាំក្រុងព្រះសីហនុ មានទីលំនៅមុនពេលចាប់ខ្លួន ផ្ទះលេខ ២០អឺ០ ផ្លូវលេខ ២០០ សង្កាត់បឹងរាំង ខណ្ឌដូនពេញក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ឃុន ងួន "ស" ម្ដាយឈ្មោះ ម៉ៅ ណៃ "រ" នៅលីវ ទោសពីមុនគ្មាន ឃុំខ្លួនកាលពីថ្ងៃទី ២០-០១-១៩៩៨ ។

..មានមេធាវី លោក ខៀវ សិញផន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ គីម ហិន "ចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤៦ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិព្រែកមហាទេព ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

..មេធាវី គ្មាន ។

---- ---

- តាមពាក្យបណ្ដឹង ចុះថ្ងៃទី ០៤-៩-១៩៨៦ របស់ឈ្មោះ គីម ហ៊ន ជាបងស្រី និង ជាអាណាព្យាបាល របស់ជនរងគ្រោះឈ្មោះ គីម ប៊ុនណា ប្ដឹងពីជនមិនស្គាល់មុខ និង បក្សពួកដែលបាន ធ្វើឃាតមកលើប្អូនប្រុសខ្លួនឈ្មោះ គីម ប៊ុនណា កាលពីថ្ងៃទី ០៦-០៨-១៩៨៦ នៅចន្លោះពីម៉ោង៣ ទៅម៉ោង៤ ទាបភ្លឺនៅមុខផ្ទះលេខ ២២អឺ០ ផ្លូវលេខ ២០០ ក្រុមទី៦ សង្កាត់បឹងរាំង ខណ្ឌដូនពេញ។ ខ្លួនសំណូមពរសុំទាមទារការខូចខាតអនាគតក្រុមគ្រួសារ ជាទឹកប្រាក់ ១០ ម៉ឺនដុល្លារអាមេរិក ជម្ងឺចិត្ត និង ប្រាក់ឧបត្ថម្ភគ្រួសារចិញ្ចឹមកូន និង ចំណាយលើបុណ្យសពចំនួន ៥ម៉ឺនដុល្លារអាមេរិក ខាតបង់ទ្រព្យ សម្បត្តិគ្រឿងអលង្ការ ២០ពាន់ដុល្លារអាមេរិក សរុប ១៧០ពាន់ដុល្លារអាមេរិក ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ អម តុលាការក្រុងភ្នំពេញ ថា :

១- ចោទប្រកាន់លើឈ្មោះ ឃុន សុធី ហៅ ក្ដាម ភេទប្រុស អាយុ ២៨ឆ្នាំ ពីបទ សម្លាប់ មនុស្សដោយគិតទុកជាមុន និង ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៦-០៨-១៩៨៦ បទ ល្មើសដែលមានចែងអោយផ្ដន្ទាទោសតាមមាត្រាទី៣១ និង ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- បង្គាប់បណ្ដឹងអាជ្ញាលើគូកន "គ្មានសាវតាជាតិ" ពីបទសម្លាប់មនុស្សដោយគិតទុកជាមុន និង ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ០៦-៨-១៩៨៦ បទល្មើសដែលមានចែងអោយផ្ដន្ទា-ទោសតាមមាត្រាទី ៣១ និង ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៧១ "ខ" ចុះថ្ងៃទី ០៤-១១-១៩៨៧ របស់តុលាការ ក្រុងភ្នំពេញ ដែលមានខ្លឹមសារសេចក្ដីសំរេចដូចតទៅ :

១- ផ្ដន្ទាទោសឈ្មោះ ឃុន សុធី ហៅ ក្ដាម ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ កើតនៅ ភូមិព្រែកថ ឃុំព្រែកថ ស្រុកពញាឮព្រែកថ ខេត្តកំពង់ចាម កំរិតវប្បធម៌ជាប់មធ្យមសិក្សាកំរិត២ សាលា ព្រះពុទ្ធ ទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ២០អឺ០ ក្រុមទី៦ ផ្លូវលេខ២០០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុង ភ្នំពេញ ។ ឪពុកឈ្មោះ ឃុន ងុន "ស" ម្ដាយឈ្មោះ ម៉ៅ រឿណ "រ" នៅលីវ ដាក់ពន្ធនាគារ កំណត់ ១០ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ពីបទសម្លាប់មនុស្សគិតទុកជាមុន និង ប្លន់ បទល្មើសដែលមានចែង និង ផ្ដន្ទា-ទោស តាមបញ្ញត្តិមាត្រា ៣១ , ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពី ថ្ងៃទី ០៦-០៨-១៩៨៦ ។

២- អោយឈ្មោះ ឃុន សុធី ហៅ ក្ដាម សងទ្រព្យសម្បត្តិដែលបាត់បង់ សរុបជាទឹកប្រាក់ - ២៤.៣០០ដុល្លារអាមេរិក និង ជម្ងឺចិត្ត ០១ម៉ឺនដុល្លារអាមេរិក ទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ គីម ហ៊ន សំណូមពរលើសពីនេះត្រូវបដិសេធចោល ។ បើជននេះរឹងរូសមិនព្រមសង ត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ធនទណ្ឌ តាមច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣- វត្ថុតាងមាន :

- រថយន្តម៉ាកតូយូតាស្ត្រីនធ័រ ពណ៌ស ០១គ្រឿង
- ម៉ូតូរ៉ឺទ្យា លេខ ៨៨០០ អ៊ីច ០១គ្រឿង
- នាឡិកាដៃម៉ាកហ្គោលស្តារប្រើថ្ម ០១គ្រឿង
- ចិញ្ចៀនធ្វើពីលោហធាតុ ពណ៌លឿង និង ទង់ដែង ៣វង់ត្រូវរឹបអូសដើម្បីធានាសំណង។

----- -----

- អាវុធខ្លីផុន កា៥៤ គ្មានលេខ ០១ ដើម
- មួកថ្នាក់វរៈសេនីយ៍ ០២
- សក្តិថ្នាក់វរៈសេនីយ៍ ០១ ត្រូវប្រគល់អោយឈ្មោះ យុន សុធី វិញ
- ក្រមា ០២
- ក្រណាត់ស្រោមពូកប្រឡាក់ឈាម ០១ ត្រូវរឹបអូសបំផ្លាញចោល ។

៤ - សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៧១ "ខ" ចុះថ្ងៃទី ០៥ - ១១ - ១៩៩៧ របស់ឈ្មោះ គឹម ហ៊ិន ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ ៧១ "ខ" ចុះថ្ងៃទី ០៥ - ១១ - ១៩៩៧ របស់តុលាការក្រុងភ្នំពេញ - ត្រង់ចំណុចទី២ អំពីសំណងជម្ងឺចិត្ត ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៨ "ខ" ចុះថ្ងៃទី ២៥ - ១១ - ១៩៩៧ របស់មេធាវីការពារអោយជនជាប់ចោទ ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ ៧១ "ខ" ចុះថ្ងៃទី ០៥ - ១១ - ១៩៩៧ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា :

១ - ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៥ - ១១ - ១៩៩៧ របស់លោកមេធាវី ខៀវ សិល្បផន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុស និង គតិច្បាប់ ។

២ - ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ - ១១ - ១៩៩៧ របស់ឈ្មោះ គឹម ហ៊ិន ជាដើមបណ្តឹងទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣ - តម្កល់សាលក្រមព្រហ្មទណ្ឌ លេខ ៧១ "ខ" ចុះថ្ងៃទី ០៥ - ១១ - ១៩៩៧ ទុកជាបានការពេញទាំងមូល ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៦៤ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១១ - ១១ - ១៩៩៧ របស់ឈ្មោះ គឹម ហ៊ិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹង គតិច្បាប់ ។

២ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៥ - ១១ - ១៩៩៧ របស់មេធាវី លោក ខៀវ - សិល្បផន ជាមេធាវីរបស់ឈ្មោះ យុន សុធី ហៅ ក្តាម ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹង គតិច្បាប់ ។

៣ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៧១ "ខ" ចុះថ្ងៃទី ០៥ - ១១ - ១៩៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ដោយគ្រាន់តែលប់មាត្រាទី ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលក្នុងចំណុចទី១ នៃសេចក្តីសំរេចចោល ។ ចំណុចក្រៅពីនេះតម្កល់ទុកជាបានការដដែល ។

៤ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង សាទុក្ខតាមកំណត់ច្បាប់ ។

----- -----

- បានឃើញបណ្តឹងសាទុក្ខលេខ ៥៨ ចុះថ្ងៃទី ០១ - ៧ - ១៩៩៩ របស់លោកមេធាវី ខៀវ សិញ្ញផន មេធាវីការពារអោយជនជាប់ចោទ ប្តឹងមិនសុខចិត្តសាលដីកាព្រហ្មទណ្ឌលេខ ១៦៤ ចុះថ្ងៃទី ២៥ - ៦ - ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណារបស់មេធាវីការពារអោយជនជាប់ចោទឈ្មោះ ឃុន សុធី ហៅ ក្តាម ចុះថ្ងៃទី ១៩ -១៩ - ១៩៩៩ ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា :

១ - មានពិរុទ្ធភាព និង ភស្តុតាងគ្រប់គ្រាន់លើឈ្មោះ ឃុន សុធី ហៅ ក្តាម ពីបទ មនុស្សឃាត ដោយចេតនាគិតទុកជាមុន ពិតប្រាកដមែន ។

២ - តម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- បានស្តាប់សារណារបស់ជនជាប់ចោទឈ្មោះ ឃុន សុធី ហៅ ក្តាម

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី ខៀវ សិញ្ញផន ការពារអោយជនជាប់ចោទ ថា : ស្នងតាមសារណារបស់ខ្ញុំ បញ្ជាក់អោយឃើញថា : តាមចម្លើយសាក្សីខ្លះថាជនជាប់ចោទមានគ្នា ៥នាក់ ឯសាក្សីខ្លះទៀតថា មានគ្នា៣នាក់ ហេតុនេះតុលាការមិនអាចយកជាការបានទេ ។ តាមចម្លើយសាក្សីឃើញហេតុការនិយាយថា ឃើញមនុស្សម្នាក់ភ្ជង់មនុស្សម្នាក់ទៀត ហើយឃើញមនុស្សម្នាក់ផ្សេងទៀត ចីរបស់ម៉្យាងដាក់ក្នុងរថយន្ត ។ មានសាក្សីម្នាក់ទៀតឆ្លើយ ថាបានឮជនជាប់ចោទគំរាមថា កុំមាត់ប្រយ័ត្នអញសំលាប់ចោល ហើយជនជាប់ចោទបានគំរាម ឃុន សុធី ថាមិនអោយរាយការណ៍ប្រាប់ប៉ូលីស បើហ៊ាន ថា សំលាប់ចោលទាំងពូជ ដូច្នេះឃុន សុធី ត្រូវបង្ខំចិត្តពុំរាយការណ៍ប្រាប់ប៉ូលីសដើម្បីការពារសុវត្ថិភាពក្រុមគ្រួសាររបស់ខ្លួន ។

សំណូមពរតុលាការកំពូលបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ ហើយសូមអោយកូនក្តីខ្ញុំបានរួចផុតពីការចោទប្រកាន់ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការថា : ការលើកឡើងរបស់លោកមេធាវីគ្មានភស្តុតាងផ្ទុយសូមតុលាការសំរេចតាមច្បាប់ចុះ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥៨ ចុះថ្ងៃទី ០១ - ៧ - ១៩៩៩ របស់លោកខៀវ - សិញ្ញផន មេធាវីការពារជនជាប់ចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយកបណ្តឹងនេះមក -

- - - - - - - - - -

ជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលឈ្មោះ ឃុន សុធី ហៅ ក្តាម កំពុងជាមេធាវីដែរដែលលើកឡើងក្នុងសារណាចុះថ្ងៃទី១៩ - ១០ - ១៩៩៩ ថាជនជាប់ចោទឈ្មោះ ឃុន សុធី ហៅ ក្តាម ធ្វើសកម្មភាពក្នុងអំពើល្មើសដោយសារតែមានការគំរាមកំហែងពីឈ្មោះ រ៉ា និង បក្សពួករបស់ឈ្មោះ រ៉ា នោះតុលាការកំពូលពុំអាចពិចារណាបានឡើយដោយហេតុថាក្រោយពីឈ្មោះ ឃុន សុធី ហៅ ក្តាម ចុះពីរថយន្តនៅកន្លែងលើកអាល់ទែ ក្បែរសង្កាត់បឹងរាំងនោះមកឈ្មោះនេះ លែងមានការគំរាមកំហែងទៀតហើយ ប៉ុន្តែឈ្មោះនេះនៅតែព្យាយាមបន្តយករថយន្តទៅអោយឈ្មោះ រ៉ានៅព្រែកឯងម្តងជាពីរដង មិនបានជួបហើយរហូតដល់បើកឡានតាមមនុស្សម្នាក់ជិះម៉ូតូនាំមុខអោយទៅជួបឈ្មោះ រ៉ា រួចខ្លួនបានប្រគល់សោរឡានទៅអោយឈ្មោះ រ៉ា នៅម្តុំអាងទឹកអូឡាំពិកទៀតផង ហើយខ្លួនព្យាយាមគេចខ្លួនរហូតទាល់តែសមត្ថកិច្ចស្រាវជ្រាវរកឃើញ និង ចាប់ខ្លួនបាន ។ ម្យ៉ាងទៀតជនជាប់ចោទ និង មេធាវីរបស់ខ្លួនពុំមានភស្តុតាងណាបញ្ជាក់ថាពិតជាមានការគំរាមកំហែងទេ ។

- យល់ឃើញថា ឈ្មោះ ឃុន សុធី ហៅ ក្តាម មានតួនាទីជានគរបាលពិតជាយល់ដឹងច្បាស់ណាស់អំពីសមត្ថកិច្ចដោះស្រាយ ហើយខ្លួនស្នាក់នៅជិតអធិការដ្ឋាននគរបាលខណ្ឌដូនពេញស្រាប់ ប៉ុន្តែបែរជាយករលេសថាខ្លួនបានទៅរាយការណ៍ពីហេតុការណ៍នេះជូនអង្គភាពធ្វើការរួចហើយ ពុម្យ៉ាងទៀតលិខិតបញ្ជាក់លេខ ០៨៤ប្រទ ចុះថ្ងៃទី ៣១ - ៧ - ១៩៩៨ របស់លោក អ៊ុន បូរ៉ា ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ នៃក្រសួងមហាផ្ទៃដែលបញ្ជាក់ថាឈ្មោះ ឃុន សុធី ហៅ ក្តាម បានមករាយការណ៍ផ្ទាល់មាត់ដែរ ក៏ទើបធ្វើនៅថ្ងៃទី ៣១ - ៧ - ១៩៩៨ គឺក្រោយថ្ងៃកើតហេតុអស់រយៈពេលជិតពីរឆ្នាំហើយ ។ ដូច្នេះតុលាការកំពូលពុំអាចលើកយកលិខិតនេះមកធ្វើជាភស្តុតាងដោះបន្ទុកអោយជនជាប់ចោទបានឡើយ ។

- យល់ឃើញថា ជនជាប់ចោទបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីរបស់ជនជាប់ចោទ ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី ពុំបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនទេ ហើយក៏ពុំបានមកចូលរួម នាសវនាការនេះដែរ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៦៤ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៩៩របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីកំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ .

១ - ទទួលបណ្តឹងសាទុក្ខលេខ ៥៨ ចុះថ្ងៃទី ០១ - ៧ - ១៩៩៩ របស់លោក ទៀវ -

----- -----

កិច្ចនេះ មេធាវីការពារអោយជនជាប់ចោទឈ្មោះ ឃុន សុធី ហៅ ក្តាម ទុកជាត្រឹមត្រូវតាមទំនងច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ខុស នឹង គតិច្បាប់ ។

២ - តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៦៤ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៨ ខែ តុលា - ឆ្នាំ ២០០០ ។